# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌលេខ **៤០៥៩**
ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២២
-សំណុំរឿងស៊ើបសួរលេខ **៣០៩២**
ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០២២
-សំណុំរឿងជំនុំជម្រះលេខ **៤០៩៥**
ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២
-សាលក្រមលេខ **៥៩ "ហ" ក្រ៣**
ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ឋានៈអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ឋានៈចៅក្រមសាលាដំបូងរាជធានីភ្នំពេញជាចៅក្រមប្រឹក្សា
-លោកស្រី [redacted] ឋានៈចៅក្រមសាលាដំបូងរាជធានីភ្នំពេញជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ឋានៈព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៥៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] **បូរ៉ា** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៧.១០.២០០៤ ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើត ភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្លូវលំ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **ជាមរ៉េត** "រ" ម្តាយឈ្មោះ [redacted] **ចាន់ធី** "រ" នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **៦៧៩២ "ប" ជ.ឃ.ជ** ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ (ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ "ម១") ។

-ត្រូវបានដាក់ក្រោមការពិនិត្យ ពីបទ: **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៤១** នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី ៖** ឈ្មោះ [redacted] **កន្និកា** ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៧.០៩.១៩៨៨ ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើត សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ១៥១A ផ្លូវលំ ភូមិស្រុកចេក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** ។
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ៤៥ នាទី ក្មេងស្រីរងគ្រោះ [redacted] **មីមី**



Scanned with CamScanner

អាយុ ១២ឆ្នាំ កំពុងតែនៅក្នុងសាលារៀនវេសឡាញ ផ្លូវ២៧១ ស្ថិតនៅភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** ភេទប្រុស អាយុ ១៨ឆ្នាំ បានប្រើទូរស័ព្ទលេខ ០១៦ ៧៥៨៦៨៣ ទូរស័ព្ទទៅក្មេងស្រីរងគ្រោះបបួលទៅហូបអីនៅម៉ាតការ៉ាំសាំងតូតាល់ ក្បែរសាលាខាងលើដែរ ហើយជនជាប់ចោទក៏បានបើកម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ទៅយកក្មេងស្រីរងគ្រោះ ពីសាលាទៅអង្គុយហូបអីនៅក្នុងម៉ាតរយៈពេលប្រហែល ២០នាទី ជនជាប់ចោទបានបបួលក្មេងស្រីរងគ្រោះទៅផ្ទះ ដើម្បីណែនាំឱ្យឪពុកម្តាយរបស់គេស្គាល់ រួចជនជាប់ចោទក៏បានបើកម៉ូតូឌុបជនរងគ្រោះទៅដល់ផ្ទះស្ថិតនៅភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ពេលទៅដល់ជនជាប់ចោទបាននិយាយលួងលោមក្មេងស្រីរងគ្រោះថា រូបគេស្រលាញ់ក្មេងស្រីរងគ្រោះ ហើយចង់បានធ្វើជាគូអនាគត ប៉ុន្តែក្មេងស្រីរងគ្រោះមិនទាន់បាននិយាយឆ្លើយតបជាមួយជនជាប់ចោទទេ ស្រាប់តែជនជាប់ចោទបានចាប់ទាញដៃក្មេងស្រីរងគ្រោះចូលក្នុងបន្ទប់ រួចចាប់ដោះសម្លៀកបំពាក់ក្មេងស្រីរងគ្រោះចេញទាំងអស់ ហើយជនជាប់ចោទបានស្រាតខោចេញដែរ តែមិនបានដោះអាវចេញទេ រួចធ្វើសកម្មភាពរំលោភសេពសន្ថវៈមកលើក្មេងស្រីរងគ្រោះ ជាបន្តបន្ទាប់ក្នុងពេលតែមួយបានសម្រេចចំនួន ០២លើក ក្រោយពីជនជាប់ចោទបាននិយាយប្រាប់ក្មេងស្រីរងគ្រោះ កុំឱ្យប្រាប់ឪពុកម្តាយ ឬ អ្នកដទៃឱ្យបានដឹង រួចនៅវេលាម៉ោង ១៣ និង៣០នាទី ថ្ងៃខែឆ្នាំដដែលជនជាប់ចោទក៏បានឌុបក្មេងស្រីរងគ្រោះត្រឡប់ទៅសាលារៀនវិញ រហូតដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០ នាទី ម្តាយក្មេងស្រីរងគ្រោះមានការសង្ស័យមកលើក្មេងស្រីរងគ្រោះរឿងគេចសាលាមិនចូលរៀន កាលពីថ្ងៃកើតហេតុខាងលើ ក៏បានសួរនាំក្មេងស្រីរងគ្រោះ ទើបក្មេងស្រីរងគ្រោះរៀបរាប់អំពីហេតុការណ៍ខាងលើប្រាប់ឪពុកម្តាយបង្កើតឱ្យបានដឹង ហើយឈ្មោះ ជា ស្រេង ភេទប្រុស អាយុ ៤០ឆ្នាំ (ត្រូវជាឪពុកបង្កើតរបស់ក្មេងស្រីរងគ្រោះ) ក៏បាននាំក្មេងស្រីរងគ្រោះមករាយការណ៍ប្រាប់សមត្ថកិច្ច និងបានដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលខណ្ឌដង្កោតែម្តង ក្រោយមកសមត្ថកិច្ចបានស្រាវជ្រាវឃាត់ខ្លួនជនជាប់ចោទខាងលើបានត្រង់ចំណុចផ្ទះគ្មានលេខ ស្ថិតនៅភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ យកមកធ្វើការសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌដង្កោ តាមនីតិវិធីច្បាប់ ។

-**បានឃើញ** របាយការណ៍សំយោគលេខ **០៧៦/២២ រ.ប.ក** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៣០៨១ អ.យ.ណ** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៣៩៨៧ អ.យ.ណ** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ **៥២៨៤ "ប" ដ.ដ** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** បានឆ្លើយថា៖ ខ្លួនបានស្គាល់ឈ្មោះ [redacted] **មីមី** តាមរយៈប្រៀនហ្វេសបុកជាមួយគ្នា ហើយខ្លួនក៏បានឆាតលេងជាមួយគ្នាទៅវិញទៅមករហូតដល់ក្លាយជាសង្សាជាមួយគ្នារយៈពេលមួយឆ្នាំកន្លះមកហើយ ។ ខ្លួនបានជួបគ្នាផ្ទាល់ជាមួយឈ្មោះ [redacted] **មីមី** ប្រហែល ១០ដងក្នុងមួយខែ ហើយពេលជួបម្តងៗភាគច្រើនជួបគ្នានៅម៉ាត រួចខ្លួនបាននាំឈ្មោះ **មីមី** ទៅលេងផ្ទះរបស់ខ្លួនហើយចង់ឱ្យស្គាល់ឪពុកម្តាយរបស់ខ្លួនផង ។ ខ្លួន និងឈ្មោះ **មីមី** ពិតជាស្រលាញ់គ្នាដោយពិតប្រាកដមែន ។ នៅថ្ងៃកើតហេតុខ្លួនបានទៅយកឈ្មោះ **មីមី** ពីសាលារៀនវេសឡាញទៅអង្គុយលេងញ៉ាំអីនៅម៉ាត ពេលញ៉ាំអីហើយខ្លួនបានបបួលឈ្មោះ **មីមី** ទៅផ្ទះរបស់ខ្លួននៅភូមិសំបួរ ពេលដែលទៅដល់ផ្ទះរបស់ខ្លួនក៏បានជួប



Scanned with CamScanner

ជាមួយម៉ាក់របស់ខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះជាមួយអ៊ុំហើយឈ្មោះ **មីមី** បានជម្រាបសួរម៉ាក់របស់ខ្លួនរួចក៏បានដើរចូលទៅក្នុងផ្ទះជាមួយខ្លួនរួចក៏បានចូលទៅក្នុងបន្ទប់របស់ខ្លួននិយាយគ្នាលេងបានមួយសន្ទុះ ខ្លួនក៏បានសុំឈ្មោះ **មីមី** រួមភេទ ហើយឈ្មោះ **មីមី** បានយល់ព្រម ខ្លួនមិនបានចាប់បង្ខំ រឺគំរាមកំហែងអ្វីទេ ខ្លួន និងឈ្មោះ **មីមី** រួមភេទជាមួយគ្នាបានចំនួន ០២ដងហើយឈ្មោះ **មីមី** មិនបានស្រែកទេ ។ បន្ទាប់ពីរួមភេទជាមួយគ្នារួចហើយខ្លួនបានជូនឈ្មោះ **មីមី** ទៅសាលារៀនវិញ ។ ក្រោយមកទៀតខ្លួន និងឈ្មោះ **មីមី** ក៏បានទាក់ទងគ្នាធម្មតាបានប្រហែលរយៈពេលបីខែខ្លួនបានឈ្លោះគ្នាជាមួយ **មីមី** ខ្លួនក៏ឈប់ទាក់ទងជាមួយគាត់ទៀត ទើបធ្វើឱ្យគាត់ប្រាប់រឿងរ៉ាវទាំងអស់ដែលខ្លួនបាននៅជាមួយគាត់ទៅប៉ាម៉ាក់របស់គាត់ ដូច្នេះ ប៉ាម៉ាក់គាត់បានប្តឹងដល់សមត្ថកិច្ចឱ្យឃាត់ខ្លួនតែម្តង ។

-ជនរងគ្រោះឈ្មោះ [redacted] **មីមី** ឆ្លើយថា៖ ខ្លួនបានស្គាល់ឈ្មោះ [redacted] **បូរ៉ា** តាមរយៈហ្វេសបុក ដំបូងរាប់អានគ្នាធម្មតាយូរៗទៅទើបស្រលាញ់គ្នាជាសង្សា ។ តាំងពីស្គាល់គ្នាមកខ្លួន និងឈ្មោះ [redacted] **បូរ៉ា** មិនសូវបានជួបគ្នាញឹកញាប់ទេមួយអាទិត្យជួបគ្នាបានតែ ២ ទៅ ៣ដង ប៉ុណ្ណោះ ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] **បូរ៉ា** បានបបួលខ្លួនទៅផ្ទះរបស់គាត់ ដោយបានប្រាប់ខ្លួនថាចង់ណែនាំខ្លួនឱ្យឪពុកម្តាយគាត់បានស្គាល់ ខ្លួនក៏យល់ព្រមទៅជាមួយឈ្មោះ [redacted] **បូរ៉ា** ។ ពេលទៅដល់ផ្ទះរបស់ឈ្មោះ [redacted] **បូរ៉ា** ក៏បានជួបម្តាយរបស់គាត់ ខ្លួនបានជម្រាបសួរម្តាយគាត់ហើយឈ្មោះ [redacted] **បូរ៉ា** ក៏បាននាំខ្លួនចូលទៅក្នុងបន្ទប់របស់គាត់បន្ទាប់មកខ្លួន និងឈ្មោះ [redacted] **បូរ៉ា** បានរួមភេទជាមួយគ្នាដោយមានការព្រមព្រៀងគ្នាមិនមានអ្នកណាបង្ខិតបង្ខំខ្លួនទេ ។ បន្ទាប់ពីថ្ងៃកើតហេតុមកខ្លួន និងឈ្មោះ [redacted] **បូរ៉ា** នៅតែមានទំនាក់ទំនងជាមួយគ្នាធម្មតា តែដោយសារតែមានការឈ្លោះប្រកែកគ្នាឈ្មោះ [redacted] **បូរ៉ា** ក៏បានទុកខ្លួនចោលឈប់ទាក់ទងមកខ្លួន ទើបខ្លួនខឹងហើយក៏បានដាក់ពាក្យបណ្តឹងឈ្មោះ [redacted] **បូរ៉ា** តែម្តង ។ ខ្លួននៅតែស្រលាញ់ឈ្មោះ [redacted] **បូរ៉ា** ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **កន្និកា** ឆ្លើយថា: ខ្លួនបានសួរនាំកូនស្រីឈ្មោះ [redacted] **មីមី** អំពីការគេចសាលានៅម៉ោងសិក្សាកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពេលនោះកូនស្រីខ្លួនបានប្រាប់ថា ឈ្មោះ [redacted] **បូរ៉ា** ភេទប្រុស បានទូរស័ព្ទមកកូនស្រីខ្លួនបានបបួលកូនស្រីខ្លួនទៅផ្ទះរបស់គាត់ ពេលទៅដល់ឈ្មោះ [redacted] **បូរ៉ា** បាននិយាយលួងលោមកូនខ្លួន និងបបួលកូនខ្លួនចូលបន្ទប់រួចចាប់ដោះសម្លៀកបំពាក់កូនខ្លួនចេញទាំងអស់ រួចក៏បានធ្វើសកម្មភាពរំលោភសេពសន្ថវៈមកលើកូនស្រីខ្លួនបានសម្រេច ០២ដង ក្រោយពីកូនស្រីប្រាប់រឿងហេតុខាងលើឱ្យបានដឹងរួច ខ្លួនក៏បាននាំកូនស្រីមករាយការណ៍ប្រាប់សមត្ថកិច្ច និងដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលខណ្ឌតែម្តង ។ តែនៅពេលនេះខ្លួនសុំដកពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ នៅអធិការដ្ឋាននគរបាលខណ្ឌដង្កោវិញ ដោយហេតុថាកូនខ្លួន និងជនជាប់ចោទបានស្រលាញ់គ្នាជាយូរណាស់មកហើយពេលនេះខ្លួន និងឪពុកម្តាយរបស់ជនជាប់ចោទបានសម្របសម្រួលគ្នាថានាថ្ងៃអនាគតនឹងរៀបចំផ្សំផ្គុំកូនទាំងពីរនាក់ឱ្យក្លាយទៅជាប្តីប្រពន្ធស្របច្បាប់ ។ សំណូមពរសុំឱ្យតុលាការដោះលែងជនជាប់ចោទឱ្យមានសេរីភាពឡើងវិញ ដើម្បីអាចមានឱកាសបានសិក្សាសារជាថ្មី ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់ជនជាប់ចោទ ចម្លើយបំភ្លឺរបស់ជនរងគ្រោះ ព្រមទាំងបានពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ឃើញថានៅក្នុងសំណុំរឿងនេះតំណាងអយ្យការមិនកែប្រែបទចោទប្រកាន់នោះទេ គឺស្នើសុំតម្កល់បទចោទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ និងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ **៣៩៨៧ អ.យ.ណ** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ទុកជាបានការដដែល ដូច្នេះសុំឱ្យលោកចៅក្រមជំនុំជម្រះមេត្តាពិនិត្យ និង សម្រេចតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] **បូរ៉ា** បានរួមភេទជាមួយជនរងគ្រោះឈ្មោះ **មីមី** ដោយមានការព្រមព្រៀង និងគ្មានការបង្ខិតបង្ខំ រឺការអូសទាញអ្វីនោះទេ មួយវិញទៀតដោយកូនក្តីខ្លួនជាអនីតិជនដែលមានអាយុទើបតែ១៧ឆ្នាំ ហើយគាត់ក៏កំពុងនៅសិក្សារៀនសូត្រផងត្រូវបន្តការសិក្សាទៀត ម្យ៉ាងវិញ



Scanned with CamScanner

ទៀតជនរងគ្រោះក៏បានដកពាក្យបណ្ដឹងរួចហើយដែរ ដូច្នេះខ្លួនសូមសំណូមពរដល់លោកចៅក្រមមេត្តាលើកលែងបទចោទប្រកាន់ដល់កូនក្ដីខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានធ្វើសំណូមពរជាសម្ដីចុងក្រោយថា: ខ្លួនសូមសំណូមពរសុំលោកចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង និងឆាប់បានឱ្យខ្លួនត្រឡប់ទៅផ្ទះវិញដើម្បីបន្តការសិក្សាឡើងវិញ ។

-ក្រោយពីបានស្ដាប់ ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្ដាប់ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យ ភស្ដុតាង

-ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់ ជនជាប់ចោទធ្វើសំណូមពរជាសម្ដីចុងក្រោយ

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងរាជធានីភ្នំពេញ
## យល់ឃើញថា

១-កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ៤៥ នាទី ក្មេងស្រីរងគ្រោះ [redacted] **មីមី** អាយុ ១២ឆ្នាំ កំពុងតែនៅក្នុងសាលារៀនវេសឡាញ ផ្លូវ២៧១ ស្ថិតនៅភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** ភេទប្រុស អាយុ ១៨ឆ្នាំ បានទូរស័ព្ទទៅក្មេងស្រីរងគ្រោះបបួលទៅហូបអីនៅម៉ាតកាហ្វេសាំងតូតាល់ ក្បែរសាលាខាងលើ ពេលអង្គុយហូបអីបានរយៈពេលប្រហែល ២០នាទី ជនជាប់ចោទបានបើកម៉ូតូឌុបជនរងគ្រោះទៅដល់ផ្ទះស្ថិតនៅភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ពេលទៅដល់ជនជាប់ចោទបាននិយាយលួងលោមជនរងគ្រោះហើយ ស្រាប់តែជនជាប់ចោទចាប់ទាញដៃក្មេងស្រីរងគ្រោះចូលក្នុងបន្ទប់ រួចចាប់ដោះសម្លៀកបំពាក់ក្មេងស្រីរងគ្រោះចេញទាំងអស់ ហើយបានធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈមកលើក្មេងស្រីរងគ្រោះជាបន្តបន្ទាប់ក្នុងពេលតែមួយបានសម្រេចចំនួន ០២លើក ក្រោយពេលជនជាប់ចោទបាននិយាយប្រាប់ជនរងគ្រោះកុំឱ្យប្រាប់ឪពុកម្ដាយ ឬ អ្នកដទៃឱ្យបានដឹង ក្រោយមករហូតដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ម្ដាយក្មេងស្រីជនរងគ្រោះមានការសង្ស័យ ក៏បានសួរនាំជនរងគ្រោះក៏បានដឹងរឿង ហើយក៏បានដាក់ពាក្យបណ្ដឹងនៅអធិការដ្ឋានខណ្ឌដង្កោតែម្ដង ។

**២**-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** ឆ្លើយថា: ខ្លួន និងឈ្មោះ **មីមី** ពិតជាស្រលាញ់គ្នាដោយពិតប្រាកដមែន ។ នៅថ្ងៃកើតហេតុខ្លួនបានទៅយកឈ្មោះ **មីមី** ពីសាលារៀនវេសឡាញទៅអង្គុយលេងញុំាអីនៅម៉ាត ពេលញុំាអីហើយខ្លួនបានបបួលឈ្មោះ **មីមី** ទៅផ្ទះរបស់ខ្លួននៅភូមិសំបួរ ពេលដែលទៅដល់ផ្ទះរបស់ខ្លួនបានក៏បានជួបជាមួយម៉ាក់របស់ខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះជាមួយអ៊ុំហើយឈ្មោះ **មីមី** បានជម្រាបសួរម៉ាក់របស់ខ្លួនរួចក៏បានដើរចូលទៅក្នុងផ្ទះជាមួយខ្លួនរួចក៏បានចូលទៅក្នុងបន្ទប់របស់ខ្លួននិយាយគ្នាលេងបានមួយសន្ទុះ ខ្លួនក៏បានសុំឈ្មោះ **មីមី** រួមភេទហើយឈ្មោះ **មីមី** បានយល់ព្រម ខ្លួនមិនបានចាប់បង្ខំ រឺគំរាមកំហែងអ្វីទេ ខ្លួន និងឈ្មោះ **មីមី** រួមភេទជាមួយគ្នាបានចំនួន ០២ដងហើយឈ្មោះ **មីមី** មិនបានស្រែកទេ ។

៣-តាមចម្លើយដើមបណ្ដឹងឈ្មោះ [redacted] **កន្និកា** ឆ្លើយថា: បន្ទាប់ពីកូនស្រីខ្លួនបានរៀបរាប់ប្រាប់ពីរឿងហេតុដែលឈ្មោះ [redacted] **បូរ៉ា** បានរំលោភមកលើរូបកូនខ្លួនរួចហើយ ខ្លួនក៏បានរាយការណ៍មកសមត្ថកិច្ចដើម្បីប្ដឹងលើឈ្មោះ [redacted] **បូរ៉ា** ។



Scanned with CamScanner

តែនៅពេលនេះខ្លួនសុំដកពាក្យបណ្ដឹងវិញហើយ ដោយសារកូនខ្លួន និងឈ្មោះ [redacted] **បូរ៉ា** បានស្រលាញ់គ្នារួចទៅហើយ ម្យ៉ាងវិញទៀត ឪពុកម្ដាយរបស់ជនជាប់ចោទបានសម្របសម្រួលគ្នាថានាថ្ងៃអនាគតនឹងរៀបចំផ្សំផ្គុំកូនទាំងពីរនាក់ឱ្យក្លាយទៅជាប្ដីប្រពន្ធស្របច្បាប់ ។

**៤**-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **មីមី** ឆ្លើយថា: ខ្លួនបានស្គាល់ឈ្មោះ [redacted] **បូរ៉ា** តាមរយៈហ្វេសបុកដំបូងរាប់អានគ្នាធម្មតាយូរៗទៅទើបស្រលាញ់គ្នាជាសង្សារ ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] **បូរ៉ា** បានបបួលខ្លួនទៅផ្ទះរបស់គាត់ ដោយបានប្រាប់ខ្លួនថាចង់ណែនាំខ្លួនឱ្យឪពុកម្ដាយគាត់បានស្គាល់ ខ្លួនក៏យល់ព្រមទៅជាមួយឈ្មោះ [redacted] **បូរ៉ា** ។ ពេលទៅដល់ផ្ទះរបស់ឈ្មោះ [redacted] **បូរ៉ា** ក៏បានជួបម្ដាយរបស់គាត់ ខ្លួនបានជម្រាបសួរម្ដាយគាត់ហើយឈ្មោះ [redacted] **បូរ៉ា** ក៏បាននាំខ្លួនចូលទៅក្នុងបន្ទប់របស់គាត់បន្ទាប់មកខ្លួន និងឈ្មោះ [redacted] **បូរ៉ា** បានរួមភេទជាមួយគ្នាដោយមានការព្រមព្រៀងគ្នាមិនមានអ្នកណាបង្ខិតបង្ខំខ្លួនទេ ។

**៥**-តាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ជនរងគ្រោះ, ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងបានបង្ហាញអោយឃើញថា គឺជនជាប់ចោទ និងជនរងគ្រោះពិតជាបានរួមភេទជាមួយគ្នាដោយមានការព្រមព្រៀងគ្នាគ្មានភស្តុតាងមួយណាបញ្ជាក់ថាជនជាប់ចោទបង្ខិតបង្ខំ, គំរាមកំហែង ឬឆ្លៀតឱកាសទៅលើជនរងគ្រោះនោះទេ ។

**៦**-តាមសំបុត្រកំណើតលេខ ០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១០ របស់ជនរងគ្រោះឈ្មោះ [redacted] **មីមី** កើតថ្ងៃទី១៧ ខែមករា ឆ្នាំ២០១០ បង្ហាញថាជនរងគ្រោះមានអាយុជាង ១២ឆ្នាំ (ក្រោមអាយុ ១៥ឆ្នាំ គិតត្រឹមថ្ងៃប្រព្រឹត្តបទល្មើស ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ )។

**៧**-ជនជាប់ចោទមានស្មារតី និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើព្រហ្មទណ្ឌ ។ អំពើរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយរបស់បុគ្គល ដែលច្បាប់បញ្ញត្តិថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវបានផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**៨**-គ្មានធាតុផ្សំគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** ពីបទ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ** តែមានធាតុផ្សំបទល្មើសគ្រប់គ្រាន់លើឈ្មោះ [redacted] **បូរ៉ា** ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ដូច្នេះគប្បីកែប្រែបទចោទប្រកាន់ ។

**៩**-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ មិនកែប្រែបទចោទប្រកាន់ និងបានប្ដឹងសុំចោទប្រកាន់លើជនជាប់ចោទតាមដីកាសន្និដ្ឋានស្ថាពរដដែល គប្បីលើកយកមកពិចារណា ។

**១០**-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] **ចាន់រិទ្ធ** បានធ្វើសេចក្ដីសន្និដ្ឋានថា ឃើញថាកូនក្ដីខ្លួន និងជនរងគ្រោះស្រលាញ់គ្នា ហើយបានព្រមព្រៀងគ្នាដោយមិនមានការបង្ខិតបង្ខំ រឺគំរាមកំហែងអ្វីនោះទេ ដូច្នេះខ្លួនសុំសំណូមពរអោយក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាលើចំណុចទាំងអស់នេះ ហើយឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់ពុំមានលក្ខណៈត្រឹមត្រូវឡើយ ។

**១១**-ដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ពាក្យដកពាក្យបណ្ដឹងឈប់ប្ដឹងទៅលើជនជាប់ចោទទៀតហើយ ដូច្នេះតុលាការពុំពិចារណាទៅលើសំណងជម្ងឺចិត្តអ្វីទេ ។

**១២**-តាមសំបុត្រកំណើតលេខ ៤៣៣ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ដង្កោជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** កើតថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៤ មានអាយុ ១៧ឆ្នាំ ៨ខែ ៨ថ្ងៃ ជាអនីតិជន គប្បីពិចារណាសម្រេចសម្រាលទោសពាក់កណ្ដាលស្របតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

**១៣**-ពិនិត្យឱ្យដិតដល់ជនជាប់ចោទទើបប្រព្រឹត្តបទល្មើសជាលើកដំបូង និងបានទទួលស្គាល់នូវកំហុសរបស់ខ្លួនគប្បីផ្ដល់ឱកាសឱ្យបានកែប្រែខ្លួន ដោយសម្រាលទោសខ្លះ ។



Scanned with CamScanner

**ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ**

**<u>វិនិច្ឆ័យសេចក្តី</u>**

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] **បូរ៉ា** ភេទប្រុស កើតថ្ងៃទី០៧.១០.២០០៤ ជនជាតិខ្មែរ ពីបទ **រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទឹងជនរងគ្រោះ** តាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ មកជាបទ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ។

**២**-ផ្តន្ទាទោសលើឈ្មោះ [redacted] **បូរ៉ា** ភេទប្រុស កើតថ្ងៃទី០៧.១០.២០០៤ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ** តែអនុវត្តទោស **០១ឆ្នាំ** ទោសដែលនៅសល់ត្រូវព្យួរទោសធម្មតា ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុច ផ្ទះគ្មានលេខ ផ្លូវលំ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **បូរ៉ា** និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាអសាធារណៈ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ។

បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខានិងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner